Disability Rights California

*ប្រព័ន្ធការពារ និង គាំពារនៅកាលីហ្វ័រញ៉ា*

www.disabilityrightsca.org

ទូរស័ព្ទឥតបង់ប្រាក់៖ (800) 776-5746

TTY៖ (800) 719-5798

---

## # 1 សន្លឹកព័ត៌មានអំពីការកាត់ថវិការនៅកាលីហ្វ័រញ៉ាចំពោះ ការអប់រំ K-12 – 6 សីហា 2009

## ការប្រឡងចេញ CAHSEE

ខិតប័ណ្ណនេះពិពណ៌នាអំពីការផ្លាស់ប្តូរដែលបានធ្វើឡើងតាមរយៈដំណើរការថវិការនៅកាលីហ្វ័រញ៉ា។ ការផ្លាស់ប្តូរទាំងនេះជាប់ទាក់ទងនឹងការប្រឡងចេញពីវិទ្យាល័យ CAHSEE។ ការផ្លាស់ប្តូរទាំងនេះចាប់មានប្រសិទ្ធិភាពនៅដើមនៃឆ្នាំសិក្សា 2009-2010។

### តើច្បាប់បានផ្លាស់ប្តូរដូចម្តេច?

ច្បាប់មុនបានចែងថាសិស្សគ្រប់រូបក្នុងរដ្ឋកាលីហ្វ័រញ៉ាត្រូវតែប្រឡងជាប់ការប្រឡងចេញពីវិទ្យាល័យ CAHSEE ដើម្បីទទួលសញ្ញាបត្រវិទ្យាល័យ។ ច្បាប់ថ្មីលើកលែងសិស្សពិការដែលទទួលសិទ្ធិ ពីការប្រឡងជាប់ CAHSEE។ ការណ៍នេះមានន័យថាសិស្សដែលបំពេញតាមលក្ខណៈវិនិច្ឆ័យនៃសិស្សដែលទទួលសិទ្ធិ អាចទទួលសញ្ញាបត្រវិទ្យាល័យដោយមិនចាំបាច់ប្រឡងជាប់ CAHSEE។ សិស្សពិការនៅតែត្រូវប្រឡង CAHSEE ក្នុងថ្នាក់ទី 10 ដោយសារគោលបំណងដែលថា គ្មានក្មេងណាម្នាក់នៅពីក្រោយច្បាប់ឡើយ។ ក្រមអប់រំ ផ្នែក 60852.3(e)។ សិស្សពិការក៏ត្រូវខំប្រឹងសម្រាប់ការប្រឡង CAHSEE នៅថ្នាក់ទី 12 ផងដែរ។

## នរណាគឺជា "សិស្សដែលទទួលសិទ្ធិ"?

សិស្សដែលទទួលសិទ្ធិត្រូវបានកំណត់ថាជាសិស្សដែលមាន IEP ឬ គម្រោង 504 ដែលបង្ហាញថាសិស្សនោះគ្រោងនឹងទទួលសញ្ញាបត្រវិទ្យាល័យ ហើយសិស្សនោះបានបំពេញ ឬ នឹងបំពេញតម្រូវការរបស់រដ្ឋ និង តម្រូវការក្នុងស្រុកផ្សេងទៀតទាំងអស់សម្រាប់ការទទួលសញ្ញាបត្រវិទ្យាល័យនៅ ឬ បន្ទាប់ពីថ្ងៃទី 1 កក្កដា 2009។ ក្រមអប់រំ ផ្នែក 60852.3(c)។

## តើវាមានន័យដូចម្តេចដែលថាសិស្សត្រូវបំពេញតម្រូវការរបស់រដ្ឋ និង តម្រូវការក្នុងស្រុកផ្សេងទៀតទាំងអស់?

សិស្សត្រូវតែបំពេញកិច្ចការក្នុងវគ្គសិក្សា និង ក្រេឌីតចាំបាច់ ដែលបានតម្រូវដោយច្បាប់រដ្ឋដើម្បីទទួលសញ្ញាបត្រវិទ្យាល័យ។ តម្រូវការតែមួយគត់ដែលខុសគេនោះគឺថាការប្រឡងជាប់ CAHSEE គឺមិនចាំបាច់ឡើយ។ តម្រូវការកិច្ចការក្នុងវគ្គសិក្សា និង ក្រេឌីតជាក់លាក់ដែលអនុវត្តចំពោះមណ្ឌលសាលារៀនរបស់អ្នកអាចរកបានដោយការស្នើសុំវាពីមណ្ឌលសាលារៀននោះ។

## តើការលើកលែងនេះមានប្រសិទ្ធិភាពក្នុងរយៈពេលប៉ុន្មាន?

ការលើកលែងនេះនឹងមានប្រសិទ្ធិភាពរហូតដល់ក្រុមប្រឹក្សាអប់រំរដ្ឋអនុវត្តតាមវិធីផ្សេងនៃបទបញ្ញត្តិសម្រាប់សិស្សពិការដែលទទួលសិទ្ធដើម្បីបង្ហាញអំពីកម្រិតនៃការសម្រេចការសិក្សាតាមបទដ្ឋានមាតិកាដែលតម្រូវឲ្យប្រឡងជាប់ CAHSEE ឬ រហូតទាល់តែក្រុមប្រឹក្សានោះសម្រេចថាវិធីផ្សេងនោះមិនអាចធ្វើបាន។ ក្រមអប់រំ ផ្នែក 60852.3(b)។ តាមច្បាប់ថ្មីនេះ ដែលសន្មតថាចាប់ផ្តើមនៅថ្ងៃទី 1 មករា 2011 សិស្សពិការដែលទទួលសិទ្ធិអាចចូលរួមក្នុងការធ្វើតេស្តផ្សេងនោះ។ ទោះជាយ៉ាងនេះក្តី តាមបទបញ្ញត្តិ ក្រុមប្រឹក្សាអប់រំរដ្ឋអាចបន្លាយកាលបរិច្ឆេទនេះដល់ទៅពីរឆ្នាំ ប្រសិនបើក្រុមប្រឹក្សាសម្រេចថាការបន្លាយពេលនោះគឺចាំបាច់សម្រាប់ការអនុវត្តន៍ដ៏សមស្របលើបទបញ្ញត្តិដែលទទួលយកការធ្វើតេស្តផ្សេងនោះ។ ក្រមអប់រំ ផ្នែក 60852.2(b)។